# ក្រសួងអប់រំឡុងប៊ីច

## LONG BEACH UNIFIED SCHOOL DISTRICT

SERVING LONG BEACH, LAKEWOOD, SIGNAL HILL AND AVALON

ការិយាល័យអគ្គនាយកសាលា

1515 HUGHES WAY
LONG BEACH, CALIFORNIA 90810-1839
(562) 997-8242 • FAX (562) 997-8280


ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩

សូមជំរាបមកដល់មាតាបិតានិងអ្នកអាណាព្យាបាលសិស្ស៖

នៅថ្ងៃនេះក្រសួងសុខាភិបាលប្រចាំក្រុងឡុងប៊ីចបានផ្តល់ដំណឹងមកយើងថាគេបានរកឃើញសិស្សពីរនាក់បានកើតរោគគ្រុនផ្តាសាយជ្រូក H1N1 គឺម្នាក់នៅសាលាមធ្យមសិក្សា ហាមៀលថុន និងម្នាក់ទៀតនៅសាលាវិទ្យាល័យ ជ័រដិន ។

យោងទៅតាមមន្ត្រីមើលការខុសត្រូវផ្នែកសុខភាព សិស្សទាំងពីនាក់នោះមានជំងឺស្រាលទេ ហើយត្រូវបានឃាំងឲ្យនៅពីអ្នកដ៏ទៃភ្លាមៗ បានទទួលការព្យាបាល ហើយបានជាសះមកវិញហើយប្ចូនទៅប្រាំថ្ងៃក្រោយមក។ សាលារៀនទាំងអស់នៅតែបើកទ្វារបង្រៀនដដែល។ យើងសូមរំលឹកលោកអ្នកអំពីសារៈសំខាន់នៃការអនុវត្តនូវវិធីបង្ការការពារឲ្យមានសុខភាពនិងសុវត្ថិភាពដូចខាងក្រោមនេះ៖

- កុំចេញពីផ្ទះ បើលោកអ្នកមិនស្រួលខ្លួន ឬមានរោគសញ្ញាដូចគ្រុនផ្តាសាយ( ក្តៅខ្លួន ឈឺខ្លួនប្រាណ ក្អកនិងហៀរសំបោរ)។ សូមប្រាប់សាលារៀនឲ្យដឹងបើកូនឈប់មិនទៅរៀន។
- លាងដៃឲ្យបានញឹកញាប់ហើយបាំងមាត់ឲ្យជិតពេលក្អកនិងកណ្តាស។
- រក្សាចំងាយយ៉ាងតិចមួយម៉ែត្រពីអ្នកមានជំងឺ។
- រក្សាភាពស្ងប់ស្ងៀមហើយណែនាំកូនលោកអ្នកឲ្យរក្សាភាពស្ងប់ស្ងៀមដែរ។

ថ្វីបើក្រសួងអប់រំនៅតែបន្តបើកទ្វារធ្វើការជាធម្មតាក៏ដោយ យើងសូមរំលឹកឲ្យក្រុមគ្រួសាររៀបចំគ្រោងទុកជាមុនសំរាប់ពេលមានអាសន្នហើយរៀបចំផែនការសំរាប់ការថែរក្សាកូននៅផ្ទះ បើសិនជាចាំបាច់។ ការសំរេចបិទទ្វារសាលារៀនណាមួយនឹងត្រូវធ្វើឡើងដោយបានគិតគូយ៉ាងដិតដល់ជាមួយនឹងការណែនាំពីក្រសួងសុខាភិបាលប្រចាំក្រុងឡុងប៊ីច ហើយនឹងប្រាប់ឲ្យលោកអ្នកដឹងជាបន្ទាន់។

យើងដឹងហើយថា ពេលនេះគឺជាពេលដែលគួរឲ្យខ្វល់ខ្វាយមួយនៅក្នុងសហគមន៏យើង។ សូមទុកចិត្តចុះថាយើងកំពុងប្រតិបត្តិនូវវិធានការបង្ការការពារយ៉ាងដឹតដល់ដើម្បីថែរក្សាសុខុមាលភាពរបស់សិស្សានុសិស្សនិងបុគ្គលិកយើងទាំងអស់។ ពេលណាមានព័ត៏មានថ្មីៗ យើងនឹងផ្តល់បន្តជូនលោកអ្នកជាបន្ទាន់។

ដើម្បីព័ត៏មានក្បោះក្បាយថែមទៀត សូមចូលទៅគេហទំព័ក្រសួងអប់រំ នៅ www.lbschools.net ដែលមានទំព័រពិសេសមួយសម្រាប់តែអំពីរឿងគ្រុនជ្រូកនេះតែប៉ុណ្ណុះ។ បើលោកអ្នកមានសំនួរអ្វីមួយក្រោយពីបានទទួលព័ត៏មាននេះ លោកអ្នកអាចទូរស័ព្ទទៅលេខប្រចាំពេលអាសន្នរបស់ក្រសួងអប់រំ នៅលេខ 562 997-8000 លេខបន្ត 7176 ។

សូមអរគុណដល់ការគាំទ្ររបស់លោកអ្នកមកដល់សាលារៀនយើង។

ដោយសេចក្តីគោរព

Christopher J. Steinhauser

Christopher J. Steinhauser
អគ្គនាយកសាលា